សង្គមស៊ីវិលពិភាក្សាពីស្ថានភាពប្រជាធិបតេយ្យនៃខួបពាក់កណ្តាលឆ្នាំកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

ដោយ ដានី កែវ - October 22, 2026

ទិដ្ឋភាពក្រុមប្រឹក្សាអង្គការសង្គមស៊ីវិលដែលធ្វើការលើកកម្ពស់សិទ្ធិសេរីភាព ធ្វើកិច្ចសន្ទនាតុការហ្វេ ឬ Cafe Talk និងបានផ្សព្វផ្សាយតាមបណ្តាញសង្គម កាលពីថ្ងៃទី២១ តុលា ២០២១។ រូបភាព រាជបុក

0:00 / 6:23

ក្រុមមន្ត្រីអង្គការសង្គមស៊ីវិលនៅកម្ពុជា បានបើកវេទិកាជជែកពិភាក្សាគ្នាក្នុងឱកាសប្រារព្ធខួបពាក់កណ្តាលឆ្នាំនៃ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក្រោមប្រធានបទ «សារៈសំខាន់នៃការធានាឱ្យបាននូវគោលនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ដើម្បីសន្តិភាព ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍរបបសិទ្ធិមនុស្សនៅកម្ពុជា»។ ក្រុមអង្គការសង្គមស៊ីវិល ក៏ត្រៀមនឹងប្រារព្ធពិធីធំមួយ នៅថ្ងៃ២៥ តុលា ខាងមុខ ដើម្បីរំលឹកទិវាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។

ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការលើកកម្ពស់សិទ្ធិសេរីភាព បានបើកកិច្ចសន្ទនាតុការហ្វេ ឬ Cafe Talk និងបានផ្សព្វផ្សាយតាមបណ្តាញសង្គម ដោយលើកឡើង អំពីសារៈសំខាន់នៃកិច្ចព្រមព្រៀងនេះ ដែលបានកើតចេញពីការប្តេជ្ញាចិត្តមួយជាអន្តរជាតិមួយ ក្នុងការធានាឱ្យបាននូវគោលនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ការបង្រួបបង្រួមជាតិ ការគោរពសិទ្ធិមនុស្ស និងការការពារបូរណភាពទឹកដីដែលមិនមានប្រទេសណាមួយអាចរំលោភបំពានបានដាច់ដើម។

នាយកប្រតិបត្តិនៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា ក្រាក់ (CHRAC – Cambodian Human Rights Action Committee) លោក រស់ សុដ្ឋា ថ្លែង ថា កិច្ចព្រមព្រៀងអន្តរជាតិនេះ គ្មានថ្លៃអស់សុពលភាពនោះទេ បើទោះបីជាកម្ពុជាមានច្បាប់រដ្ឋធម្មនុញ្ញដែលបង្កើតឡើងដោយរដ្ឋាភិបាលដំបូងក្នុងឆ្នាំ១៩៩៣ ក្តី។ លោកថា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានចែងយ៉ាងច្បាស់អំពីការអនុវត្តនិងដំណោះស្រាយពេញលេញនៅពេលមានការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ការរំលោភអធិបតេយ្យភាពកម្ពុជា ដែលច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមិនមានចែងគ្រប់គ្រាន់ឡើយ។

លោកមើលឃើញថា កម្ពុជាអនុវត្តកិច្ចព្រមព្រៀងនេះ មិនបានពេញលេញទាំងស្រុងនោះទេ ពាក់ព័ន្ធលំហសេរីភាពរបស់ពលរដ្ឋ យុត្តិធម៌ ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស បញ្ហាព្រំដែន និងសន្តិភាពពិតប្រាកដជាដើម។

> *លោក រស់ សុដ្ឋា៖ «ហើយឃើញអស់លោកខ្លះគាត់មានឥទ្ធិពលនយោបាយ ដូច្នេះលោក បើសិនជាលោកនិយាយទៅវាត្រូវលុសត្រាប់ប្រទេសជាតិ សម្រាប់អ្នកជំនាន់ក្រោយ យើងបណ្តុះពូជល្អសម្រាប់ខ្មែរយើង។ តែបើសិនជាយើងនិយាយខុស គឺយើងនាំអ្នកប្រទេសជាតិយើងទៅខុស អត់ត្រូវ គឺត្រាប់ពូជអត់ល្អ។ ច្បាប់ទាំង២ហ្នឹងអត់មានអីខ្វាស់គ្នាទេ ហើយធម្មតា ការដែលយើងឯកភាពគ្នាហើយ គឺបានន័យថាហើយ វាអាចនឹងមានការរំលោភ ឬក៏ការអនុវត្តមិនសម មិនត្រឹមត្រូវដែលយើងត្រូវក្រឡែកទៅលើសេចក្តីប្តេជ្ញាចិត្ត ទាំងអស់នុងឡើងវិញ ដើម្បីឲ្យឆ្ពោះទៅរកការអនុវត្តឲ្យបានប្រសើរ។»*

លោក រស់ សុដ្ឋា ទទូចឲ្យអ្នកនយោបាយគ្រប់និន្នាការ និងប្រជាពលរដ្ឋ ឈប់ក័ន្ត្រច្រល់ និងបញ្ឈប់ការបកស្រាយខុសអំពីកិច្ចព្រមព្រៀងនេះ ថា អស់សុពលភាព ពោលមិនអាចប្រើប្រាស់បាន ដើម្បីកុំឲ្យអ្នកជំនាន់ក្រោយយល់ខុសតាម។

នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) លោក សេង សុវឌ្ឍនា បង្ហាញក្តីបារម្ភថា ការធ្វើវិសោធនកម្មច្បាប់ញឹកញាប់ពេកនៅកម្ពុជា អាចធ្វើឲ្យរបូតខ្លឹមសារសំខាន់ពាក់ព័ន្ធនឹងសេរីពហុបក្ស។ លោកថា ដើម្បីទទួលបានសន្តិភាពពិតប្រាកដ មិនមែនគ្រាន់តែបញ្ចប់សង្គ្រាមមួយមុខនោះទេ គឺត្រូវមានការគោរពសិទ្ធិមនុស្ស ប្រជាធិបតេយ្យ នីតិរដ្ឋឲ្យបានពេញលេញ។ លោកសង្កេតឃើញថា ការអនុវត្តសិទ្ធិនៅកម្ពុជា ដូចជាសិទ្ធិបញ្ចេញមតិ សិទ្ធិជួបជុំគ្នា សិទ្ធិក្នុងផ្សព្វផ្សាយព័ត៌មាន ជាដើម គឺស្ថិតក្នុងស្ថានភាពមួយរឹតបន្តឹង និងការធ្វើទុក្ខបុកម្នេញតាមគ្រប់រូបភាព។

> *លោក សេង សុវឌ្ឍនា៖ «ការអនុវត្តច្បាស់នៅក្នុងការគោរពសិទ្ធិ លំហាពលរដ្ឋ លំហាសិទ្ធិនយោបាយនេះ គឺថា មិនត្រូវមានសូរ៉ស់ជាង២ទេ បើថា មាន១ក្រុមគេធ្វើបែកក្រុមទាប់ហាប់ម៉ុនៗ ប៉ុន្តែមួយក្រុមទៀត គ្រាន់តែសុំធ្វើកិច្ចការអីវិទាក់មួយអី នៅទីលានប្រជាធិបតេយ្យ មិនអនុញ្ញាតឲ្យគ្នាទៅធ្វើកន្លែងនេះ ធ្វើកន្លែងនោះ ទៅកន្លែងធ្វើការនៅអីក្រោមពិធីរៀបចិ្នងនៅការិយាល័យរបស់ខ្លួនអីចឹង១យើងមើលថា អាហ្នឹងវាសូរ៉ស់ជាង២។ ការលណា វាមានសូរ៉ស់ជាង២ អាហ្នឹងចំណោតសូរថា កន្លែងណាដែលយើងថា ជាស្ថានតិបង្រួបបង្រួមជាតិ? ចឹងអាការអនុវត្តច្បាប់ផ្លូវណាតិសើរតិចនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសហ្នឹង។»*

ជាមួយគ្នានេះ ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក នី សុខា បានលើកឡើងថា ខ្វីមសារកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស សំខាន់ចំនួនពាក់ណុច គឺ ទី១ និយាយអំពីកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយរួមនៃជម្លោះកម្ពុជា ទី២ និយាយអំពីកិច្ចព្រមព្រៀងស្តីអំពីអធិបតេយ្យភាព ឯភាពជុំវិញ និងអាណុប្រកិត្តភាពជាដើម ហើយទីជា គឺអំពីការស្តារឡើងវិញពីការកសាងប្រទេសជាតិ។ លោកថា កិច្ចព្រមព្រៀងនេះ បានធានាដល់សន្តិសុខក្នុងតំបន់ ហើយដើម្បីដោះស្រាយបញ្ហាប្រទេសជាតិ ឲ្យមានការអភិវឌ្ឍន៍បាន ច្បាប់ត្រូវអនុវត្តឲ្យស្មើភាពគ្នា តម្លាភាព និងមិនមានអំពើពុករលួយជាដើម។

លោកមើលឃើញថា អ្នកនយោបាយខ្មែរបច្ចុប្បន្ន គឺមានការបែកបាក់គ្នា ដោយអ្នកនយោបាយមួយចំនួនបាននិរទេសខ្លួនទៅក្រៅប្រទេស មានការចាប់ខ្លួនពាក់ពន្ធនាគារ គណបក្សនយោបាយមួយចំនួនត្រូវបានរំលាយ និងមិនអាចចូលរួមប្រកួតប្រជែងបាន និងការធ្វើទុក្ខបុកម្នេញផ្សេងៗ។

> *លោក នី សុខា៖ «ខ្មែរយើងគួរដល់ពេលផ្លាស់ផ្សាយជាតិហើយ ចំណុចគន្លឹះសំខាន់គឺការផ្លាស់ផ្សាយជាតិឲ្យមានស្មារតីជាតិសិន ដើម្បីវាកកទៅជជែកគ្នា រកវិធីក្នុងការប្រកួតប្រជែងគ្នា អំណាចគ្នា ដោយយុត្តិធម៌ នៅពេលនៅបញ្ហាសិទ្ធិមនុស្សក៏ត្រូវដោះស្រាយ អីបញ្ហាអធិបតេយ្យភាពក៏ត្រូវដោះស្រាយ បញ្ហាយុត្តិធម៌សង្គមក៏ត្រូវបានដោះស្រាយ ជាមួយគឺកាចនឹងដោះស្រាយបានបញ្ហាព្រំនេរណាស់ បើសិនយើងមានអាហ្នឹង។ សូមឲ្យអ្នកនយោបាយវៃឆ្លាសកកទៅជជែកគ្នារកគន្លឹះឯកភាពជាតិមួយដើម្បីឲ្យឯកភាពទៅរៀបចំចំណើរការបោះឆ្នោតឲ្យបានល្អ ត្រឹមត្រូវ។»*

កន្លងមក សង្គមស៊ីវិល និងអ្នកវិភាគមួយចំនួនក៏បានមើលឃើញពីវិបត្តិធំៗជាច្រើនដោយសារការបែកបាក់ផ្ទៃក្នុងកម្ពុជា ដូចជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ រឹតត្បិតសេរីភាពប្រជាពលរដ្ឋ អំពើពុករលួយក្នុងស្ថាប័នរដ្ឋ បក្សពួកនិយមដែលធ្វើឲ្យកុដិចុះទន់ខ្សោយ ហក្នុងត្រូវបានចៃណ្ណានពាន និងបានកាន់កាប់ទឹកដីខ្មែរចំនួន៩៥ ទីតាំង។ ប៉ុន្តែទោះមានការណ្ណានពានបែបនេះក្តី ក៏រដ្ឋាភិបាលកម្ពុជាមិនអើពើយកបញ្ហានេះ ដោះស្រាយរួមជាមួយប្រទេសហតួលេខនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងប្តឹងចៃទៅតុលាការអន្តរជាតិដែរ។

ពលករខ្មែរនៅក្រៅប្រទេសជាច្រើនក៏បានធ្វើបាតុកម្មតវ៉ាតាមបណ្តាប្រទេសនានា ដូចជា ជប៉ុន កូរ៉េ អូស្ត្រាលី និងកាណាដាជាដើម ទាមទារឲ្យរដ្ឋាភិបាលកម្ពុជាអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឲ្យបានត្រឹមត្រូវ លើកលំហសេរីភាពពលរដ្ឋ គោរពសិទ្ធិមនុស្ស និងដោះលែងអ្នកទោសនយោបាយជាង១០០នាក់ ដែលកំពុងជាប់ឃុំដោយសារការប្រើប្រាស់សិទ្ធិរបស់ខ្លួនផងដែរ៕

ស្លាក កិច្ចព្រមព្រៀងសន្តិភាព២៣ តុលា ចលនាខ្មែរដើម្បី ប្រជាធិបតេយ្យ ច្បាប់